២–ធ្វើការចរចាជាមួយភាគីថៃពីលទ្ធភាពនៃការប្រើប្រាស់ និង អភិវឌ្ឍន៍ធនធានរ៉ែក នៃស្ទឹងមេទឹក (មណាម) ដើម្បីជាផលប្រយោជន៍នៃប្រទេសទាំងពីរ ។

៣–ទំនាក់ទំនងស្វែងរកជំនួយពីអង្គការអន្តរជាតិ និងពីបណ្ដាប្រទេសនានា ។

៤–ពិនិត្យសិក្សាជ្រើសរើសក្រុមហ៊ុនឯកជនដែលមានលទ្ធភាពធ្វើការសិក្សាស្រាវជ្រាវ បច្ចេកទេសជាបឋម (Prefeasibility study) និងសិក្សាស្រាវជ្រាវអំពីលទ្ធភាពកសាងគំរោង (feasibility study) ។

៥–ពិនិត្យជ្រើសរើសក្រុមហ៊ុនដែលអាចមានលទ្ធភាពធ្វើវិនិយោគក្នុងការងារនេះ ។ រួចធ្វើរបាយការណ៍ពីលទ្ធផលរបស់ខ្លួន ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**មាត្រា ៥ :** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធនិងសាមីជនមានភារកិច្ចទទួលអនុវត្តនូវអនុក្រឹត្យនេះចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យ លេខ : ១២ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មការដឹកនាំសំរបសំរួល និង**

**អង្គភាពអនុវត្តគំរោងការស្តារ**

**និងកែលំអអាកាសយានដ្ឋានខេត្តសៀមរាប**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ ១០៩៤.៨៣ នស/រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤.៩០ នស.រកត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុស្សារណៈយល់ដឹង ស្តីពីគំរោងការកែលំអអាកាសយានដ្ឋានសៀមរាប រវាងអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥
- តាមសំណូមពរចាំបាច់នៃការងារ

**សំរេច**

**មាត្រា ១** : បង្កើតគណៈកម្មការដឹកនាំសំរបសំរួលគំរោងការមួយ (project coordination Steering Committee) ដើម្បីផ្តល់នូវការណែនាំលើគោលនយោបាយ និង សំរួលដោះស្រាយការងារអន្តរក្រសួងរាប់បញ្ចូលទាំងកិច្ចការសំរបសំរួលការរៀបចំផែនការ និង ការអនុវត្តនៃគំរោងការស្តារ និង កែលំអអាកាសយានដ្ឋានខេត្តសៀមរាប ។

**មាត្រា ២** : គណៈកម្មការដឹកនាំសំរបសំរួលគំរោងការនេះ មានសមាសភាពដូចតទៅ ÷

| | |
|---|---|
| – ឯកឧត្តម **ម៉ម សុផារណា** អនុប្រធានអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន | សហប្រធាន |
| – ឯកឧត្តម **ម៉ុក សំអែល** អនុរដ្ឋលេខាធិការអាជ្ញាធរអាកាសចរស៊ីវិល | សហប្រធាន |
| – តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| – តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| – តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| – តំណាងក្រសួងផែនការ | សមាជិក |
| – តំណាងអាជ្ញាធរអប្សរា | សមាជិក |

-តំណាងគណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍ក្រុមប្រឹក្សា
អភិវឌ្ឍកម្ពុជា សមាជិក
-តំណាងអាជ្ញាធរដែនដីខេត្តសៀមរាប សមាជិក

**មាត្រា ៣** : គណៈកម្មការដឹកនាំសំរបសំរួលគំរោងការមានភារកិច្ចដូចតទៅ ÷

១ ផ្តល់នូវការណែនាំលើគោលនយោបាយ និង សំរួលដោះស្រាយការងារអន្តរ
ក្រសួងពាក់ព័ន្ធ ដល់គំរោងការងារនេះរាប់បញ្ចូលទាំង :
-កិច្ចការសំរបសំរួលទាំងអស់
-ការរៀបចំផែនការ
-ការគ្រប់គ្រង និង ចាត់តាំងសមត្ថកិច្ច ដើម្បីអនុវត្តនូវភារកិច្ចទាក់ទងដល់
ប្រតិបត្តិការរបស់ គំរោង

២ ត្រួតពិនិត្យលើរបាយការណ៍ប្រចាំខែ-ត្រីមាស ដែលរៀបចំឡើងដោយអង្គភាព
អនុវត្តគំរោង (PIU) និងចុះពិនិត្យផ្ទៀងផ្ទាត់ដល់ទីកន្លែង ក្នុងកាលវេលា
សមស្រប ។

៣ ត្រួតពិនិត្យលើស្ថានភាពហិរញ្ញវត្ថុរបស់គំរោង ដោយសហការជាមួយអ្នកពិគ្រោះ
ការងារប្រចាំការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង តំណាងស្ថាប័នពាក់ព័ន្ធ និង
មានរបាយការណ៍ប្រក្រតី ជូនទីស្តីការគណៈរដ្ឋមន្ត្រី ពិនិត្យ សំរេច ។

៤ ពិនិត្យ ពិចារណាលើលក្ខណៈសម្បត្តិនៃបេក្ខជនអ្នកពិគ្រោះ ឬ ទីប្រឹក្សាបរទេស
ហើយលើក យោបល់ផ្តល់អនុសាសន៍សុំការសំរេចពីសហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តី
ការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៤** : បង្កើតអង្គភាពអនុវត្តគំរោងការមួយ(Project Implementation Unit) ដើម្បី
ទទួលបន្ទុកផ្ទាល់ ការអនុវត្តន៍ , ការសំរបសំរួល និង តម្លើងរៀបចំប្រ[illegible] ការ
បរិក្ខាររបស់គំរោងការ ។ សមាសភាពនៃអង្គភាពអនុវត្តគំរោងការមានដូចតទៅ

-លោក **កែវ សាផល** អគ្គនាយកអាជ្ញាធរអាកាសចរស៊ីវិល ប្រធាន
-តំណាងអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន សមាជិក
-តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក
-តំណាងអាជ្ញាធរអាកាសចរស៊ីវិលផ្នែករដ្ឋបាល សមាជិក

-អ្នកពិគ្រោះបរទេសក្នុងការគ្រប់គ្រងគំរោងការ សមាជិក

**មាត្រា ៥ :** អង្គភាពអនុវត្តគំរោងមានភារកិច្ចដូចតទៅ ÷

-ទទួលអនុវត្តដោយផ្ទាល់សំរបសំរួល និង តម្លើងរៀបចំគំរោងការ ក្នុងការងាររដ្ឋបាលហិរញ្ញវត្ថុ និង បច្ចេកទេសជំនាញ ។

-ចុះជាប់ជាប្រក្រតី ពិនិត្យ-តាមដាន លើការងារពាក់ព័ន្ធទាំងអស់របស់គំរោងការ និង សរសេរ របាយការណ៍រៀងរាល់ខែ អំពីដំណើរប្រព្រឹត្តទៅ , ការរីកចំរើន , ចំណោទដែលកើតឡើង និង វិធីដោះស្រាយលើកជាយោបល់អនុសាន៍ជូនគណៈកម្មការដឹកនាំសំរបសំរួល ដើម្បីសុំយោបល់ សំរេចអនុម័តពីរាជរដ្ឋាភិបាល ។

-សហប្រតិបត្តិការលើការងារជាក់ស្តែង របស់គំរោងការជាមួយបណ្តាស្ថាប័នជំនាញដែលទាក់ទង ដើម្បីពិនិត្យផ្ទៀងផ្ទាត់លើរាល់លក្ខណៈបច្ចេកទេសទាំងបរិមាណ និង គុណភាព សមស្របតាមការកំណត់ ស្របតាមខ្នាតគំរូ និង បទដ្ឋានអន្តរជាតិ ក្នុងកិច្ចសន្យាជាមួយបណ្តាក្រុមហ៊ុនម៉ៅការ ។

**មាត្រា ៦ :** រចនាសម្ព័ន្ធ និង សេម៉ា របស់គណៈកម្មការដឹកនាំសំរបសំរួល និង អង្គភាពអនុវត្តគំរោង សំរាប់អាកាសយានដ្ឋានសៀមរាប ត្រូវបានជូនភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ ទី ១ និង ទី២ ។

**មាត្រា ៧ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាជ្ញាធរអាកាសចរស៊ីវិល - អាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន-អាជ្ញាធរអប្សរា-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលខេត្ត សៀមរាប និង បណ្តាស្ថាប័ន ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

**នាយករដ្ឋមន្ត្រីទី ១**
**ព្រះហស្តលេខា និងត្រា**
**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**
**ហត្ថលេខា និងត្រា**
**ហ៊ុន សែន**

* * *